# ការចុះបញ្ជីសន្ធិសញ្ញា

**(Treaty Registration)**

ដើម្បីបន្ថយនូវសន្ធិសញ្ញាសម្ងាត់ (Secret Treaty) និងធានាបាននូវតម្លាភាព មាត្រា១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ បានតម្រូវឲ្យមានការចុះបញ្ជីសន្ធិសញ្ញា។ អង្គការសហប្រជាជាតិ បានរៀបចំបទប្បញ្ញត្តិអនុវត្ត (Implementing Regulations) បន្ថែម ស្តីពីការចុះបញ្ជីសន្ធិសញ្ញា។ ចាប់ពីឆ្នាំ ១៩៤៦ មកដល់ឆ្នាំ២០០៨ មានចំនួនជាង ២៤០០ភាគ និងមានសន្ធិសញ្ញាពហុភាគី និងទ្វេភាគីចំនួនជាង ៦០០០០ នៃគ្រប់តំបន់នៃពិភពលោក ត្រូវបានចុះបញ្ជី។ ការកែសម្រួល ឬការដកខ្លួនពីសន្ធិសញ្ញា ក៏ត្រូវចុះបញ្ជីផងដែរ។

លេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ មុននឹងបោះពុម្ព ត្រូវពិគ្រោះយោបល់ជាមួយរដ្ឋដែលជាភាគីនៃសន្ធិសញ្ញា ដែលចូលជាធរមានរួចហើយ។ សន្ធិសញ្ញា ដែលត្រូវបានចុះបញ្ជី មានជាភាសាដើម (១៤០ភាសា) និងត្រូវបានបកប្រែជាភាសាបរទេស (អង់គ្លេស និង/ឬបារាំង)។ ដោយសារថវិកាមានកម្រិត ការបោះពុម្ព មិនមានវិសាលភាពទំលូទូលាយទៀតទេ (មិនបោះពុម្ពទាំងស្រុងនៃខ្លឹមសារសន្ធិសញ្ញា)។ ដូចនេះ កិច្ចព្រមព្រៀងសហប្រតិបត្តិការ (Co-operation Agreement) មិនត្រូវបានបោះពុម្ពទៀតទេ។ សម្រាប់ប្រភេទសន្ធិសញ្ញាផ្សេងពីនេះ ដូចជា រវាងអង្គការសហប្រជាជាតិ និងប្រទេស មិនត្រូវបានចុះបញ្ជីទេ ដោយសារមាត្រា១០២ ផ្តោតតែលើសន្ធិសញ្ញា ធ្វើឡើងដោយរដ្ឋភាគីនៃអង្គការសហប្រជាជាតិ។ ក្នុងករណីនេះ អង្គការសហប្រជាជាតិ នឹងធ្វើការកត់ត្រា ឬកត់សំគាល់។

មាត្រា១០២ (២) ចែងថា ប្រសិនបើមិនបានចុះ មិនអាចយកទៅសំអាងមុខស្ថាប័នអង្គការសហប្រជាជាតិទេ។ ក៏ប៉ុន្តែ វាមិនមានន័យថា សន្ធិសញ្ញានោះ គ្មានសុពលភាពទេ។ ករណីមិនអាចសំអាង ឬយ៉ាងណា មិនទាន់ត្រូវបានបំភ្លឺ ដោយតុលាការ ជាពិសេស តុលាការយុត្តិធម៌អន្តរជាតិនៅឡើយ (Concise Encyclopedia of the United Nations, UNTS-United Nations Treaty Series, 2010, pp. 833-834)។